# សាលាបឋមសិក្សា សោថហ្វក (SOUTHWARK)

1835 S. 9th Street
Philadelphia, PA 19148
**ការិយាល័យ៖ 215-952-8606**
**ទូរសារ៖ 215-952-8670**

**Andrew Lukov**, នាយកសាលា

ជូនចំពោះ ក្រុមគ្រួសារសាលា សោថហ្វក៖

ស្វាគមន៍ការត្រឡប់មកវិញសម្រាប់ឆ្នាំសិក្សា ២០១៧-២០១៨ នៅសាលា សោថហ្វក!

គោលបំណងរបស់សាលា សោថហ្វក គឺបណ្ដុះបណ្ដាលឲ្យសិស្សរបស់យើងមានភាពជាអ្នកដឹកនាំ និងអប់រំពួកគេ ដើម្បីឲ្យពួកគេរៀនបាន តាមកម្រិតថ្នាក់ និងលើសពីនេះទៅទៀត ក្នុងការអាន ការសរសេរ និង គណិតវិទ្យា និងនៅក្នុងបរិយាកាសដែលមាន សុវត្ថិភាព ស្អាតបាត និង យកចិត្តទុកដាក់ តាមរយៈនៃការគាំទ្រពី បុគ្គលិក មាតាបិតា និង សហគមន៍។ សាលា សោថហ្វក ក៏មានមោទនភាពដ៏ក្រៃលែង ដែលជាសាលាមួយក្នុងចំណោមសាលាដប់មួយ ដែលចៅហ្វាយក្រុង Kenney ជ្រើសរើសជាសាលារបស់សហគមន៍។ តាមរយៈនៃការសហការជាមួយទីក្រុងហ្វីឡាដែលហ្វ្យ៉ា យើងខ្ញុំនឹងខិតខំផ្ដល់ជំនួយដល់សិស្សានុសិស្ស និងក្រុមគ្រួសារ របស់យើងទាំងអស់។

សាលាផ្ដល់ជូនលោកអ្នកនូវឯកសារសំខាន់ៗជាបន្ត ដើម្បីជួយដល់ទំនាក់ទំនងរវាង សាលា និង មាតាបិតា និងអាចប្រើជាឯកសារយោង សម្រាប់ ច្បាប់ នីតិវិធី និង ព័ត៌មាន របស់សាលា។ សូមអានឯកសារទាំងនេះដោយយកចិត្តទុកដាក់ ហើយឧស្សាហ៍អានឡើងវិញឲ្យបានញឹកញាប់។ យើងខ្ញុំសង្ឃឹមថា លោកអ្នកយល់ថាព័ត៌មាន ទាំងនេះ មានប្រយោជន៍ និង ចាំបាច់ ចំពោះលោកអ្នក។ សូមកត់សម្គាល់ផងដែរថា នេះគឺជាឆ្នាំទីពីរនៃការអនុវត្តច្បាប់សម្រាប់ការ មករៀន និង ចេញពីរៀន ថ្មី របស់យើង ដែលជួយធ្វើយ៉ាងណាឲ្យមានសុវត្ថិភាពដល់ក្មេង របស់យើងទាំងអស់។ យើងខ្ញុំសុំឲ្យលោកអ្នកជួយគាំទ្រជាបន្តដល់ការផ្ដើមគំនិតថ្មីនេះ ដោយធ្វើតាមវិធីសាស្ត្រដែលបានចង្អុលបង្ហាញដូចតទៅនេះ។

នៅសាលា សោថហ្វក យើងឲ្យតម្លៃដល់ សមភាព ការបញ្ចូលគ្នា និង ការគោរពដល់ សេចក្ដីថ្លៃថ្នូរ និង តម្លៃ របស់សមាជិក សាលា និង សហគមន៍ របស់យើងទាំងអស់។ ដោយមិនគិតពី ពូជសាសន៍ សាសនា ស្ថានភាពអន្តោប្រវេសន៍ ភាសា ទំនោរនៃសេចក្ដីស្រឡាញ់ ការពាក់ព័ន្ធនឹងបក្សនយោបាយ ឬ វណ្ណៈ មាន ឬ ក្រ យើងគោរព និងអបអរសាទរដល់ភាពខុសៗគ្នានៅសាលា សោថហ្វក។ សាលា សោថហ្វក គឺជាកន្លែងដែលមានសុវត្ថិភាពសម្រាប់សិស្សានុសិស្ស និងក្រុមគ្រួសារ របស់យើង -- គ្មានការស្អប់ខ្ពើម គ្មានការញញើតញញើម គ្មានការសម្លុតធ្វើបាប និង គ្មានការភ័យខ្លាច។

សូមទាក់ទងមកសាលារបស់យើង បើសិនជាលោកអ្នកមានសំណួរ និង/ឬ ការបារម្ភ អ្វី។ យើងខ្ញុំទន្ទឹងរង់ចាំជួបជាមួយលោកអ្នកនៅ *យប់ជួបប្រជុំជាមួយបុគ្គលិកសាលាដំបូង* ប្រចាំឆ្នាំរបស់យើង នៅថ្ងៃពុធ ទី១៩ ខែកញ្ញា ឆ្នាំ ២០១៧ ពីម៉ោង ៥:៣០ ល្ងាច ដល់ ៧:៣០ យប់។

ដោយសេចក្ដីស្មោះស្ម័គ្រ

Andrew Lukov
នាយកសាលា